ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**

លេខ : ១០០៩/១២ ក.អ.ជ

រាជធានីភ្នំពេញ ថ្ងៃទី២៣.ខែកក្កដាឆ្នាំ២០១២.

**រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ**

**ជម្រាបមក**

**លោកស្រី ថា ណាម តំណាងសហគមន៍ជនជាតិដើមភាគតិច គ្រឹង**

**ភូមិធ្មួយទុំ ឃុំចាអ៊ុង ស្រុកអូរជុំ ខេត្តរតនគិរី**

**កម្មវត្ថុ:** ស្តីពីការទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច គ្រឹង ភូមិធ្មួយទុំ ឃុំចាអ៊ុង ស្រុកអូរជុំ

**យោង :** - លិខិតចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១១ ស្តីពីការស្នើសុំទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច គ្រឹង ភូមិធ្មួយទុំ របស់លោកស្រី ថា ណាម តំណាងសហគមន៍។

- លិខិតលេខ ៧៣៤/១១ ណ.អ.ខ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១១ ស្តីពីការទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច គ្រឹង ភូមិធ្មួយទុំ របស់អភិបាល នៃគណៈអភិបាលខេត្តរតនគីរី។
- លទ្ធផលវាយតម្លៃអត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច គ្រឹង ភូមិធ្មួយទុំ របស់ក្រុមការងារនាយកដ្ឋានអភិវឌ្ឍន៍ជនជាតិភាគតិច នៃក្រសួងអភិវឌ្ឍន៍ជនបទ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ សូមលោកស្រីជ្រាបថា ក្រសួងអភិវឌ្ឍន៍ជនបទ យល់ព្រមទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិចគ្រឹង ភូមិធ្មួយទុំ ឃុំចាអ៊ុង ស្រុកអូរជុំ ខេត្តរតនគីរី តាមសំណើ។ សហគមន៍ជនជាតិដើមភាគតិច គ្រឹង ភូមិធ្មួយទុំ អាចប្រើប្រាស់លិខិតទទួលស្គាល់អត្តសញ្ញាណនេះ ក្នុងសកម្មភាពបម្រើដល់ផលប្រយោជន៍រួមរបស់សហគមន៍ ផលប្រយោជន៍សង្គម និងផលប្រយោជន៍ជាតិ តាមការចាំបាច់ស្របតាម គោលនយោបាយ ច្បាប់ បទបញ្ញា និងលិខិតបទដ្ឋានទាំងឡាយ នៃព្រះរាជាណាចក្រកម្ពុជា។

សូមលោកស្រី ទទួលនូវសេចក្តីស្រឡាញ់រាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ។

ជា សុផារ៉ា

<u>ចម្លងជូន</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងបរិស្ថាន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងទេសចរណ៍

"ដើម្បីជូនជ្រាប"

- សាលាខេត្តរតនគីរី
- មន្ទីរអភិវឌ្ឍន៍ជនបទខេត្តរតនគីរី

"ដើម្បីមុខការ"

- ឯកសារ - កាលប្បវត្តិ



អាសយដ្ឋាន កាច់ជ្រុងផ្លូវលេខ 169 និងមហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ទូរស័ព្ទ (855) 23 884 639
ទូរសារ (855) 23 991 117 ប្រអប់សំបុត្រ 2016 គេហទំព័រ www.mrd.gov.kh អ៊ីមែល mrd.cabinet@gmail.com